# រស្មីកម្ពុជា ប្រចាំថ្ងៃ ក

\# 474 , មហាវិថីព្រះមុនីវង្ស , ភ្នំពេញ website: www.rasmeinews.com

RASMEI KAMPUCHEA DAILY NEWSPAPER

ឆ្នាំទី21 លេខ6289 ថ្ងៃពុធ ទី11 ខែធ្នូ ឆ្នាំ 2013 •ការិយាល័យគ្រប់គ្រង និងផ្សាយពាណិជ្ជកម្ម

TEL:023 726 655 Fax:023 217 172 ការិយាល័យនិពន្ធ TEL: 023 224 605 តម្លៃ1000 រៀល


# វីសិនហ្វាន់ប្រគល់រង្វាន់ធំដល់អតិថិជន

**ភ្នំពេញ** : ដើម្បីជាការថ្លែងអំណរគុណដល់អតិថិជនទាំងអស់ដែលបាននិងកំពុងប្រើប្រាស់សេវាប្រាក់កម្ចីរបស់វីសិនហ្វាន់ ហើយទទួលបានជោគជ័យចំគោលដៅក្នុងការប្រកបអាជីវកម្ម និងបានបញ្ជូនកូនចៅទៅសាលារៀន នាថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ វីសិនហ្វាន់ បានប្រគល់រង្វាន់ធំជាច្រើនដល់អតិថិជនរបស់ខ្លួន ដែលបានឈ្នះរង្វាន់ក្នុងការចាប់ឆ្នោតនាពេលកន្លងមក ។

រង្វាន់ធំម៉ូតូ៦គ្រឿង ត្រូវបានប្រគល់ជូនឈ្មោះថែម ចំរើន ឈ្មោះលក វាន់ និងអ៊ុន សុង អ្នកទាំងបីនៅខេត្តកណ្ដាល ឈ្មោះយ៉ិន សាឡី នៅខេត្តបន្ទាយមានជ័យ ឈ្មោះហ៊ុន ធឿន នៅខេត្តតាកែវ និងឈ្មោះខូ គន្ធា នៅខេត្តបាត់ដំបង ។ រង្វាន់បន្ទះសូឡា៥រង្វាន់ បានប្រគល់ជូនឈ្មោះវែង គៀង នៅខេត្តកណ្ដាល ក្ដាន់ ហ៊ុន នៅខេត្តកំពង់ឆ្នាំង តាក ជួន នៅពោធិ៍សាត់ វង យូរ នៅកំពង់ចាម និងជា ភ័ណ្ឌ នៅបាត់ដំបង ។ ក្រៅពីនោះនៅមានរង្វាន់ជាច្រើនទៀតដែលត្រូវបានវីសិនហ្វាន់ធ្វើការចាប់ឆ្នោតផ្ដល់រង្វាន់ឱ្យអតិថិជនរបស់ខ្លួនដែរ មានដូចជាកង់៣០រង្វាន់ ធុងចម្រោះទឹក៥០រង្វាន់ មួកសុវត្ថិភាព១៥០រង្វាន់ វិទ្យុ៥០រង្វាន់ និងមុងសុវត្ថិភាព១០០រង្វាន់ផងដែរ ។




*អតិថិជនប្រើប្រាស់កម្ចីសេវា របស់វីសិនហ្វាន់ ប្រាំមួយនាក់ ឈ្នះរង្វាន់ម៉ូតូ និងប្រាំនាក់ ឈ្នះរង្វាន់បន្ទះសូឡា (រូបថត:គីម ប៊ុន)*

គួរបញ្ជាក់ថា វីសិនហ្វាន់ជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែមួយគត់នៅកម្ពុជា មានបណ្ដាញប្រតិបត្តិការអន្តរជាតិ៣៥ប្រទេស ។ នៅកម្ពុជាវីសិនហ្វាន់ មានបុគ្គលិកជិត១.០០០នាក់ បម្រើសេវាហិរញ្ញវត្ថុតាមសហគមន៍ជាង១៨ម៉ឺនគ្រួសារទាំង២១ខេត្តក្រុង។

ប៊ុន